# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

(អេក្វាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

លំនាំស្ដីអំពី

# ការកសាង និង ចាត់ចែង មណ្ឌលវប្បធម៌

សម្រាប់

# នាយកសាលា និង ក្រុមចម្បាង



៣ព្រាង ខែមករា ឆ្នាំ២០០៧

ភ្នំពេញ

# មណ្ឌលវប្បធម៌

## ១, សេចក្តីផ្តើម

មណ្ឌលវប្បធម៌ជាកន្លែងមួយដែលផ្តល់ឱកាសសម្រាប់ធ្វើសកម្មភាពវប្បធម៌ជាច្រើនដែលមានស្រាប់នៅនឹងមូលដ្ឋានដែលសាលាតាំងនៅ។ តាមរយៈមណ្ឌលវប្បធម៌នេះយើងក៏រំពឹងទុកថាវានឹងជួយលើកទឹកចិត្តអោយមានការចូលរួមពីសហគមន៍ ការតែច្រើនឡើងតាមរយៈ ការជួយរៀបចំបង្កើតមណ្ឌលវប្បធម៌រហូតដល់ការប្រើប្រាស់វាអោយមានប្រសិទ្ធភាព។ មណ្ឌលវប្បធម៌ក៏អាចផ្តល់ឱកាសផងដែរសម្រាប់អោយសិស្សជួបជាមួយមិត្តភក្តិរបស់គេនៅក្នុងកន្លែងចំហមួយ មិនផ្លូវការ ដើម្បីធ្វើសកម្មភាពសិក្សា និង ធ្វើការបង្ហាញពីវប្បធម៌ ទំនៀមទម្លាប់ និង សកម្មភាពអប់រំផ្សេងទៀតនៅខាងក្រៅថ្នាក់រៀន ក៏ ដូចជាពេលទំនេរក្រៅម៉ោងសិក្សា។

## ២, គោលបំណង

ណែនាំដល់សិស្សនូវសកម្មភាពវប្បធម៌ ដើម្បីអោយគេទទួលបាននូវការយល់ដឹងពីតម្លៃនៃវប្បធម៌ចម្រុះដែលតំណាង អោយជនជាតិភាគតិចក៏ដូចជាភូមិសាស្ត្រផ្សេងៗ និង ជាកត្តាជំរុញអោយគេជួយថែរក្សា និង ធ្វើអោយមានការលូតលាស់ បន្ថែម ទៀតនៃ វប្បធម៌ចម្រុះ។ មណ្ឌលវប្បធម៌ក៏ជួយបង្កើនការយល់ដឹងពីគំនិតនៃវប្បធម៌ចម្រុះ ក្នុងចំណោមសិស្ស ក៏ដូចជាក្នុង ចំណោមសហគមន៍ និងបង្កើនការចូលរួមរបស់សហគមន៍ និង ពង្រឹងទំនាក់ទំនងរវាងសាលារៀន និង សហគមន៍។

មណ្ឌលវប្បធម៌ជាកន្លែងសម្រាប់

- សិស្សជួបគ្នាដើម្បីរៀនសូត្រ សិក្សាស្រាវជ្រាវ និង ធ្វើការបង្ហាញពីប្រធានបទនៃវប្បធម៌ផ្សេងៗដែលជាទីចាប់ អារម្មណ៍នៃក្រុម ឬ បុគ្គលម្នាក់ៗ។
- ប្រមូលផ្តុំ និង ដាក់តាំងបង្ហាញវត្ថុសិល្ប និង សិប្បកម្មផ្សេងៗ។
- លើកកំពស់ការយល់ដឹង និង ថែរក្សា វប្បធម៌ដែលមានស្រាប់ ពីបណ្តាជនជាតិផ្សេងៗដែលរស់នៅក្នុងសហគមន៍។

## ៣, លំនាំខ្លះៗក្នុងការសាងសង់មណ្ឌលវប្បធម៌

### ក/ការជ្រើសរើសទីតាំងសម្រាប់សាងសង់ មណ្ឌលវប្បធម៌

ទីតាំងសម្រាប់សាងសង់ មណ្ឌលវប្បធម៌គួរតែស្ថិតនៅក្នុងបរិវេណសាលារៀន។ ទីកន្លែងពិតប្រាកដណាមួយត្រូវតែមានការ ពិភាក្សាជាមួយអ្នកពាក់ពន្ធ័ដែលធ្វើការសម្រេចចិត្តដោយផ្អែកលើការឯកភាពគ្នាជាឯកច្ឆន្ទ។ លក្ខណវិនិច្ឆ័យសម្រាប់ធ្វើការជ្រើសរើសទីកន្លែង សម្រាប់សាងសង់ មណ្ឌលវប្បធម៌អោយបានសមស្របមួយគួរតែមាន

- ភាពងាយស្រួលក្នុងការចូលទៅដល់ ជាកន្លែងដែលងាយស្រួលចេញចូលពីគ្រប់ផ្នែកនៃសាលា ។
- សុវត្ថិភាព មិនលិចទឹកនៅរដូវវស្សា ជាកន្លែងដែលមានសន្តិសុខល្អ ។
- ទីតាំងធៀបនឹងអាគារផ្សេងទៀត មណ្ឌលវប្បធម៌មិនគួរអោយនៅដាច់ឆ្ងាយពីអាគារផ្សេងទៀតពេកទេ ។ នៅសាលារៀនខ្លះយើងអាចធ្វើការពិចារណាប្រើប្រាស់បន្ទប់ដែលមានស្រាប់សម្រាប់រៀបចំអោយទៅជាមណ្ឌល វប្បធម៌ ប្រសិនបើអាចធ្វើបាន ។

## ខ/ ទំហំរបស់មណ្ឌលវប្បធម៌

ទំហំរបស់មណ្ឌលវប្បធម៌គួរតែអាចអោយកុមារពី ១០ ទៅ ១៥ នាក់អង្គុយបាននៅក្នុងពេលតែមួយ ។ បើអាចធ្វើបានមណ្ឌលវប្បធម៌គួរតែមានទំហំពី ៤-៦ម x ៦-៨ម អាស្រ័យទៅតាមធនធានដែលមាន ។ ទំហំខាងក្នុងដែលត្រូវការចាំបាច់គឺ

- ០,៥ — ០,៧ម ពីជញ្ជាំងខាងក្រោយ និង ២ភាគ៣នៃជញ្ជាំងសងខាងត្រូវបម្រុងទុក ដាក់តុ ឬ ទ្រនើរ សម្រាប់តាំងសម្ភារ ។
- នៅផ្នែកកណ្តាលនៃមណ្ឌលវប្បធម៌គួរតែអាចអោយគេដាក់តុធំមួយជាមួយនឹង កៅអីពី ១០ — ១៥




## គ/ ផ្លង់នៃមណ្ឌលវប្បធម៌

អេស្កាប់ជំរុញលើកទឹកចិត្តអោយប្រើប្រាស់នូវវត្ថុធាតុដើមដែលមាននៅនឹងមូលដ្ឋានស្រាប់សម្រាប់ធ្វើការសាងសង់មណ្ឌលវប្បធម៌ ដែលវាជាតំណាងអោយធនធានធម្មជាតិដែលមាន និង ប្រើប្រាស់ដោយសហគមន៍នៅក្នុងតំបន់ដែលសាលារៀនតាំងនៅ ។ សាលានីមួយៗអាចជ្រើសផ្លង់ ឬ ម៉ូត្រដែលគេចូលចិត្តអាស្រ័យទៅតាមបែបផែនលំនៅស្ថានប្រពៃណីរបស់ពួកគេ និង អាស្រ័យទៅតាមចំណង់ចំណូលចិត្ត ក៏ប៉ុន្តែត្រូវមានការឯកភាពគ្នាក្នុងចំណោម គណកម្មការសាងសង់ ។

ជញ្ជាំងផ្នែកខាងក្រោយនិង ២/៣នៃជញ្ជាំងទាំងសងខាងត្រូវបិទអោយបានជិតល្អដើម្បីការពារកុំអោយទឹកភ្លៀងសាចចូលចំពោះផ្នែកជញ្ជាំងដែលនៅសល់យើងធ្វើតែផ្នែកខាងលើ និង ខាងក្រោមដោយទុកចន្លោះកណ្តាលធ្វើបង្អួច

វាជាការសំខាន់ប្រសិនបើអាចធ្វើកន្លែងរឹងមាំមួយទុករក្សាសម្ភារសំខាន់ៗដោយយើងអាចធ្វើជញ្ជាំងឬស្សីភ្នែកគ្រួច ដែលអាចអោយអ្នកទស្សនាមើលឃើញតែមិនអាចបះពាល់សម្ភារដែលដាក់តាំងក្នុងនោះបាន។
នៅជុំវិញបរិវេណមណ្ឌលវប្បធមិ គួររៀបចំអោយមានជាសួនច្បារ ធ្វើខ្ទុះដាលដាក់កៅអីសម្រាប់ទាក់ទាញសិស្ស អោយមកអង្គុយលេង និង ប្រើប្រាស់ មណ្ឌលវប្បធមិជាប្រចាំ។



## តើយើងគួរតាំងអ្វីនៅក្នុង មណ្ឌលវប្បធមិ?

ក្រោយពីបញ្ចប់ការសាងសង់ នៃ មណ្ឌលវប្បធមិគណកម្មាធិការការទ្រទ្រង់សាលារៀនត្រូវរៀបចំអោយមានប្រជុំ មួយជាមួយតំណាងសគមន៍ផ្សេងៗជាពិសេសចាស់ទុំដែលតំណាងអោយក្រុមជនជាតិភាគតិចផ្សេងៗ រស់នៅក្នុង តំបន់ដែលសាលាទទួលខុសត្រូវ ដើម្បីធ្វើការពិភាក្សាទៅអ្វីដែលពួកគេចង់ដាក់តាំងបង្ហាញដល់អ្នកទស្សនាដើម្បី អោយ គេបានយល់ដឹងអំពីទំនៀមទម្លាប់ ប្រពៃណី វប្បធមិរបស់ពួកគេ។ អ្នកសម្របសម្រួលអង្គប្រជុំ ធ្វើបញ្ជីនៃ ប្រធានបទទាំងនោះ។ ប្រធានបទដែលរំពឹងទុកគឺ

- ឧបករណ៍កសិកម្ម ដែលប្រើប្រាស់ដោយជនជាតិផ្សេងៗ
- ឧបករណ៍ប្រមាញ់, អន្ទាក់សត្វ ដែលប្រើប្រាស់ដោយជនជាតិផ្សេងៗ
- ឧបករណ៍នេសាទដែលប្រើប្រាស់ដោយជនជាតិផ្សេងៗ
- ឧបករណ៍កែរឆ្នៃផលកសិកម្ម ដែលប្រើប្រាស់ដោយជនជាតិផ្សេងៗ
- ទម្រង់សាងសង់លំនៅស្ថាន, ការរៀបចំភូមិករ
- សំលៀកបំពាក់ប្រពៃណី
- វត្ថុសិល្បៈ សិប្បកម្ម
- រឿងនិទាន ចម្រៀង និង កំណាព្យ
- ពីធីប្រពៃណី
- ប្រវត្តិ ភូមិស្រុក

អ្នកសម្របសម្រួលអង្គប្រជុំ លើកជាសំណួរថា ប្រធានបទដែលបានលើកឡើងខាងលើ តើវាមានលក្ខណៈដូចគ្នាដែរឬទេរវាងជនជាតិភាគតិចនីមួយៗ ឬ តាមតំបន់នីមួយៗ

ចម្លើយដែលរំពឹងទុកគឺ "ទេ"

អ្នកសម្របសម្រួលអង្គប្រជុំ បញ្ជាក់ភាពខុសគ្នាទាំងនោះហើយដែលមានសារសំខាន់ ដែលវាតំណាងអោយអត្តសញ្ញាណរបស់ជនជាតិ ក្រុម តំបន់ផ្សេងៗ។

អ្នកសម្របសម្រួលអង្គប្រជុំ ស្នើរអោយអ្នកចូលរួមទាំងអស់បង្កើតជាក្រុម តាម ជនជាតិ ឬ តំបន់ ដែលគេរស់នៅ ហើយក្រុមនេះមានតួនាទី ជាទីប្រឹក្សាលើផ្នែកវប្បធម៌របស់ពួកគេផ្ទាល់ និង ជួយរិះរកសម្ភារមកដាក់តាំងបង្ហាញនៅក្នុងមណ្ឌលវប្បធម៌នេះ។ សម្ភារផ្សេង ទៀតគឺជាលទ្ធផលបានមកពីការប្រមូលដោយសិស្សស្ម័គ្រចិត្ត សមាគមសិស្ស និង កម្មវិធីបំណិនជីវិត គេហកិច្ច ។ល។

## ៤/ ការតុបតែងមណ្ឌលវប្បធម៌

សម្ភារសម្រាប់ដាក់តាំងបង្ហាញនៅក្នុងមណ្ឌលវប្បធម៌ អាចជារបស់ពិត ឬ សម្បនិមិត្ត ឬ ជារូបគំនូរ រូបថតដើម្បីអោយងាយយល់ដល់អ្នកមកទស្សនា និង ការរៀនសូត្ររបស់សិស្សផង យើងត្រូវដាក់តាំងសម្ភារទាំងនោះទៅតាមប្រធានបទនីមួយៗ ដែលយើងចង់ណែនាំដូចជា ដាក់ ឧបករណ៍កសិកម្មនៅជ្រុងមួយ សំលៀកបំពាក់លើជ្រុងម្ខាងទៀតនៃជញ្ជាំង។ សម្ភារទាំងអស់ត្រូវមានផ្លាកសម្គាល់ដោយមាន កត់ត្រាឈ្មោះ ប្រភព និង មុខងារប្រើប្រាស់,.

ឈ្មោះ,..............................................

ប្រភព ............................................

និង មុខងារប្រើប្រាស់,............................

សម្រាប់សម្ភារដែលមានទំហំតូចហើយស្រាល យើងត្រូវរៀបវាដោយ បិតជាប់លើក្តាខៀនដែលមានការតុបតែងដោយក្រប និង ក្រាលគ្របដោយ កន្ទេលកក់ ឬ ក្រណាតបាវក្រចៅ (សូមមើលរូបភាព) សម្រាប់សម្ភារដែលមានទំហំធំហើយធ្ងន់ យើងអាចដាក់វាលើតុ ឬ កំរាលខ្ពស់ ធ្វើអោយប្រាកដថាវាស្ថិតនៅលើកន្លែងសួត ការពារកុំអោយខូចខាត។

រូបភាពទី១ " ឧបករណ៍កសិកម្ម និង ឧបករណ៍កែច្នៃផលកសិកម្ម"




រូបភាពទី២ " សំលៀកបំពាក់ប្រពៃណីរបស់កសិករខ្មែរ "




## ៥/ ការណែនាំពីរបៀបចាត់ចែងមណ្ឌលវប្បធម៌

- មណ្ឌលវប្បធម៌គួរតែបើកទ្វារអោយសិស្សបានចូលទស្សនាដូចម៉ោងសិក្សាធម្មតាសមាជិកក្រុមចម្បង និង នាយកសាលា មានបន្ទុកទទួលខុសត្រូវក្នុងការរៀបចំអោយមានការប្រជុំជាមួយដៃគូទាំងអស់ធ្វើអោយប្រាកដថាមណ្ឌលវប្បធម៌ត្រូវបានបង្កើតឡើង និង ដំណើរការទៅតាមការរំពឹងទុក។

- សហគមន៍ត្រូវមានតួនាទីចូលរួមក្នុងការបង្កើតមណ្ឌលវប្បធម៌ និង ជាទីប្រឹក្សាសម្រាប់នាយកសាលា និង សិស្សលើផ្នែកវប្បធម៌ ដើម្បីធ្វើអោយប្រាកដថាការរៀបរាប់ពីផ្នែកវប្បធម៌នៅក្នុងមណ្ឌលវប្បធម៌ គឺមានភាពត្រឹមត្រូវ ។
- ត្រូវបណ្តុះបណ្តាលសមាជិកសមាគមសិស្ស និង សិស្សស្ម័គ្រចិត្តដែលមកពីថ្នាក់ទី៥ និង ទី៦ ដើម្បីអោយគេមានសមត្ថភាពក្នុងការសម្របសម្រួលការប្រើប្រាស់មណ្ឌលវប្បធម៌ និង ធ្វើការដាក់វេនគ្នាមើលថែរក្សា មណ្ឌលវប្បធម៌ ។

## ៦/ ការណែនាំពីរបៀបប្រើប្រាស់មណ្ឌលវប្បធម៌

មណ្ឌលវប្បធម៌អាចត្រូវបានប្រើប្រាស់ក្នុងគោលបំណងច្រើនយ៉ាង ដោយអ្នកពាក់ព័ន្ធ ដូចខាងក្រោម

<u>គ្រូ និង សិស្សប្រើមណ្ឌលវប្បធម៌សម្រាប់</u>

- សិក្សារៀនសូត្រពីវប្បធម៌នៅក្នុងមេរៀនដែលទាក់ទងនឹងវប្បធម៌គ្រូអាចផ្តល់កិច្ចការអោយក្រុមសិស្ស អោយពួកគេ ទៅសង្កេត សម្ភារដែលដាក់តាំងនៅមណ្ឌលវប្បធម៌ ដោយដាក់ចេញនូវប្រធានបទណាមួយដូចខាងក្រោម

- តើឧបករណ៍កសិកម្មណាខ្លះ ដែលប្រើប្រាស់ដោយជនជាតិកួយ ? ខ្មែរសម័យបុរាណ?
- តើឧបករណ៍ប្រមាញ់, អន្ទាក់សត្វណាខ្លះ ដែលប្រើប្រាស់ដោយជនជាតិ កួយ ? ខ្មែរសម័យបុរាណ?
- តើឧបករណ៍នេសាទណាខ្លះដែលប្រើប្រាស់ដោយជនជាតិ ភ្នង ? កួយ ? ខ្មែរសម័យបុរាណ?
- តើបងប្អូនខ្មែរឥស្លាម ធ្វើការកិច្ចយ៉ាងដូចម្តេច?
- តើបងប្អូនខ្មែរឥស្លាម ស្លៀកសំលៀកបំពាក់អ្វីសម្រាប់ពិធីបុណ្យប្រពៃណី?

តាមរយការធ្វើទស្សនកិច្ច មណ្ឌលវប្បធម៌ សិស្សអាចរៀនសូត្របន្ថែមទៀតពីវប្បធម៌របស់ពួកគេ ក៏ដូចជាវប្បធម៌របស់មិត្តភក្តិរបស់ពួកគេបន្ថែមទៀត ។

- រៀនអានអក្សរ ជាជំនួសអោយការអានសៀវភៅនៅពេលសម្រាកកុមារតូចៗចាប់ផ្តើមប្រើប្រាស់ជំនាញអាន របស់ពួកគេ ដើម្បីអានអក្សរដែលសរសេរនៅលើសម្ភារដាក់តាំងនៅក្នុង មណ្ឌលវប្បធម៌ ។
- ធ្វើការបង្ហាញស្នាដៃរបស់ពួកគេ ឧទាហរណ៍ ក្រុមសិស្សពីក្លឹបវប្បធម៌ នៃ សមាគមសិស្សមានការ ចាប់អារម្មណ៍ លើ ឧបករណ៍ប្រមាញ់, អន្ទាក់សត្វ ដែលប្រើប្រាស់ដោយជនជាតិ ណាមួយក្នុងសម័យបុរាណ? ក្រុមនេះចាប់ផ្តើមធ្វើការស្រាវជ្រាវដោយចុះទៅតាមសហគមន៍ជនជាតិទាំងនោះ ជួបជាមួយចាស់ទុំដើម្បីធ្វើការសម្ភាសពួកគេ ធ្វើការកត់ត្រា និង ស្វែងរកសម្ភារដើម្បីធ្វើការដាក់តាំងបង្ហាញនៅក្នុងមណ្ឌល វប្បធម ។ ពួកគេត្រូវស្នើសុំនាយកសាលា និង ក្រុមចម្បងដើម្បីប្រើប្រាស់មណ្ឌលវប្បធមសម្រាប់ធ្វើការតាំងបង្ហាញរយពេល ខ្លី ឬ អចិន្ត្រៃ នូវសម្ភារដែលពួកគេធ្វើការស្រាវជ្រាវរកឃើញ ឬប្រមូលបាន និង ធ្វើការអញ្ជើញសិស្សផ្សេងទៀតមកទស្សនា ។

- ល្បែងសិក្សា ដើម្បីវាស់ស្ទង់ការយល់ដឹងពីឈ្មោះ និង មុខងារនៃសម្ភារ ដែលដាក់តាំងនៅក្នុងមណ្ឌលវប្បធម៌ នៅពេលខ្លះគ្រូអាចអាចដឹកនាំសិស្សលេង ល្បែងសិក្សាជាមួយសិស្សមកពីថ្នាក់ផ្សេងៗ ដើម្បីវាស់ស្ទង់ការយល់ដឹង ពីឈ្មោះ និង មុខងារ នៃសម្ភារ ដែលដាក់តាំងនៅក្នុងមណ្ឌលវប្បធម៌ ។
- ឧទាហរណ៍គ្រូរៀបចំសិស្សជាជួរពី១០ ទៅ១៥ នាក់ ដោយអោយសិស្សម្នាក់ៗឈនៅចំពីមុខផ្ទាំងក្រដាស់សំណួរ ដែលបិតនៅលើជញ្ជាំងដែលរៀបចំទុកដោយអ្នកសម្របសម្រួល ។ សិស្សម្នាក់ៗទទួលក្លាច់ឈើ ឬ ចំរៀកក្រដាស់ តូចៗ ចំនួន១០(សម្រាប់ ការសាកល្បងដែលមាន ១០សំណួរ)ពួកគេត្រូវអាននូវសំណួរដែលមានចម្លើយស្រាប់ ហើយដាក់ក្លាច់ឈើ ឬ ចំរៀកក្រដាស់មួយចូលទៅក្នុងប្រអប់ដែលដាក់នៅក្រោមចម្លើយដែលគេគិតថាត្រឹមត្រូវ ។ ពួកគេអាចចល័តទៅផ្ទាំសំណួរមួយទៀតបានតែនៅពេលដែលគេបានឮ ឬឃើញសញ្ញាដែលផ្តល់ដោយ អ្នកសម្រប សម្រួល ។
អ្នកសម្របសម្រួលត្រូវប្រាកដថាសិស្សទាំងអស់បានដាក់ក្លាច់ឈើ ឬ ចំរៀកក្រដាស់របស់គេចូលទៅក្នុងប្រអប់ចម្លើយរួចរាល់អស់ហើយមុននឹងផ្តល់សញ្ញាអោយពួកគេចល័តបាន។ នៅទីបញ្ចប់អ្នកសម្របសម្រួល និង សិស្សធ្វើការរាប់ចម្លើយចេញពីប្រអប់នីមួយៗដើម្បីកំណត់ថាក្រុមនេះឆ្លើយ ត្រូវបានប៉ុន្មានភាគរយ ។




សមាគមន៍សិស្ស ប្រើប្រាស់សម្រាប់ធ្វើការជួមប្រជុំ និង ធ្វើការងារជាក្រុម និង មានទួនាទីថែរក្សាការពារមណ្ឌលវប្បធមិនេះផង ។

សហគមន៍ ប្រើប្រាស់ មណ្ឌលវប្បធម៌ សម្រាប់ធ្វើការណែនាំពីវប្បធម៌របស់ពួកគេដល់ភ្ញៀវដែលមកទស្សនាភូមិ ស្រុក របស់ពួកគេ ។